**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត នាឱកាសទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ "ទីក្រុងស្អាតដើម្បីទាំងអស់គ្នា" និងពិធីប្រកាសជ័យលាភីទីក្រុងស្អាតសម្រាប់ឆ្នាំ ២០១៨-២០២១

**ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១**
**រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨**

- *ជនរួមជាតិទាំងអស់ជាទីមេត្រី !*

ខ្ញុំព្រះករុណា ខ្ញុំ មានកិត្តិយស និងសេចក្តីរីករាយជាអនេក ដែលបានចូលរួមជាមួយជនរួមជាតិទាំងអស់ អបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី៦ ឆ្នាំ២០១៨ ស្របពេលជាមួយការប្រារព្ធពិធីប្រកាសជ័យលាភីទីក្រុងស្អាតលើកទី២ សម្រាប់ឆ្នាំ២០១៨-២០២១ យ៉ាងមហោឡារិក នាពេលនេះ។

បច្ចុប្បន្នកម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់ល្អបរិបូរណ៍ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ និងមានការអភិវឌ្ឍលើគ្រប់វិស័យ ពិសេសវិស័យសេដ្ឋកិច្ច-សង្គម ដែលជាសមាសធាតុដ៏សំខាន់ក្នុងការរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដូចជា វិស័យកសិកម្ម ទេសចរណ៍ ឧស្សាហកម្មកាត់ដេរ និងសំណង់ មានការរីកចម្រើនខ្លាំង។

ជាការពិត អ្វីដែលយើងទទួលបាននាពេលនេះ គឺផ្តើមចេញពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ពិសេសនៅក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ ៩០ ក្រោមនយោបាយ "ឈ្នះ-ឈ្នះ" កម្ពុជាមិនត្រឹមតែសម្រេចបានឯកភាពជាតិ ធានាបាននូវអធិបតេយ្យភាពជាតិ បូរណភាពទឹកដី សុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គមពេញលេញនៅទូទាំងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមួយខ្ពស់ប្រកបដោយចីរភាពដែលមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ៧.៧% ជាមួយនឹងស្ថិរភាពហិរញ្ញវត្ថុ និងលំនឹងម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរទៀតផង។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាបន្តប្តេជ្ញាចិត្តក្នុងការចូលរួមជាមួយពិភពលោកទាំងមូល សម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ ហើយក៏សូមយកឱកាសនេះ ដើម្បីអបអរសាទរចំពោះសមិទ្ធផលនានាដែលសម្រេចបានតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់ភាគីពាក់ព័ន្ធទាំងផ្នែករដ្ឋ ឯកជន ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍន៍។

ដោយឡែក **ឆ្នាំ២០១៨** នេះ គឺជាឆ្នាំដ៏មានសារៈសំខាន់ជាយុទ្ធសាស្ត្រសម្រាប់កម្ពុជា ហើយត្រូវតែជាឆ្នាំដែលមានសេដ្ឋកិច្ចរឹងមាំ និងលូតលាស់ ហើយដែលយើងត្រូវចាប់ផ្តើមគិតគូរអំពីកម្មវិធីអភិវឌ្ឍន៍សម្រាប់ឆ្ពោះទៅឆ្នាំ២០៣០ ក្រោមម្លប់នៃសន្តិភាព សំដៅធ្វើយ៉ាងណាបន្តការកែលម្អជីវភាព និងការរស់នៅរបស់ប្រជាជនលើពិភពលោក និងការថែរក្សាភពផែនដីរបស់យើងសម្រាប់កូនចៅជំនាន់ក្រោយផងដែរ ដោយក្នុងនោះរបៀបវារៈសំខាន់ៗនឹងត្រូវបានយកចិត្តទុកដាក់ខ្ពស់ ជាអាទិ៍ ការកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់សុខភាព និងការអប់រំ ការគិតគូរពីនិរន្តរភាពនៅតាមបណ្តាទីក្រុង ការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ និងកិច្ចការពារអភិរក្សសមុទ្រ និងធនធានព្រៃឈើ ជាដើម។ល។

ក្នុងស្មារតីឆ្លើយតបទៅនឹងការវិវត្តន៍ និងនិន្នាការអភិវឌ្ឍន៍ថ្មីៗនេះ កម្ពុជាត្រូវបន្តយកចិត្តទុកដាក់លើការដាក់ចេញ និងអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានា ដោយប្រកាន់ខ្ជាប់នូវទស្សនទាន **"អនាគត គឺបច្ចុប្បន្ន"** ដែលចាំបាច់យើងត្រូវគិតគូរស្របពេលគ្នាគឺ៖ **ការបង្កើនឧត្តមភាពប្រកួតប្រជែង និងការធានានិរន្តរភាពនៃការអភិវឌ្ឍ។**

ឈរលើស្មារតីនៃការគិតគូរនេះ រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី២៧ ខែកុម្ភៈ ប្រារព្ធ **"ទិវាជាតិទីក្រុងស្អាត"** ជារៀងរាល់ឆ្នាំ ដើម្បីជាប្រទីបបំភ្លឺ និងក្រើនរំលឹកដល់ប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ចូលរួមក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត ដែលជាផ្នែកមួយនៃ "ព្រះរាជាណាចក្រអច្ឆរិយៈ" ក្នុងស្មារតីបណ្តុះឆន្ទៈគ្រប់ភាគីទាំងអស់គ្នាឱ្យស្រលាញ់ភាពស្អាត និងបៃតង ព្រមទាំងជំរុញចូលរួមធ្វើឱ្យទីក្រុងរបស់យើងកាន់តែស្រស់ស្អាតប្រកបដោយភាពទាក់ទាញថែមទៀត។ សម្រាប់កម្ពុជា **ទីក្រុងស្អាត ឬទីក្រុងបៃតង** គឺសំដៅដល់ទីក្រុងដែលមានបរិស្ថាន អនាម័យ សណ្តាប់ធ្នាប់ល្អ សុវត្ថិភាព គួបផ្សំនឹងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់គ្រប់គ្រាន់ដែលផ្តល់នូវភាពកក់ក្តៅ និងមជ្ឈដ្ឋានរស់នៅល្អប្រសើរសម្រាប់ប្រជាជនក្នុងទីក្រុង និងការទស្សនាកម្សាន្តរបស់ភ្ញៀវទេសចរ។ ក្នុងន័យនេះ ទីក្រុងស្អាតដែលជាស្ពានចំលងឲ្យវប្បធម៌ជួបគ្នា ជាកន្លែងដែលមានការប្រាស្រ័យទាក់ទងគ្នា ផ្លាស់ប្តូរគំនិត ព័ត៌មាន និងចំណេះដឹង ជាស្ពានចំលងឲ្យមានការតភ្ជាប់រវាងប្រជាជន និងប្រជាជនពីគ្រប់ទិសទី និងគ្រប់ជាតិសាសន៍បាននិងកំពុងដើរតួជាផលិតផលទេសចរណ៍ ជាគោលដៅទេសចរណ៍ដ៏ទាក់ទាញប្រកបដោយគុណភាព និងផ្តល់ភាពកក់ក្តៅ។

ជាក់ស្តែង ឆ្នាំនេះ គឺជាខួបលើកទី៦ នៃការប្រារព្ធទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ **"ទីក្រុងស្អាតដើម្បីទាំងអស់គ្នា"** (Clean City for All) អមជាមួយពិធីប្រកាសជ័យលាភីទីក្រុងស្អាតលើកទី២ សម្រាប់ឆ្នាំ២០១៨-២០២១។ ប្រធានបទនេះ មានអត្ថន័យរំលេចឲ្យឃើញពីអន្តរទំនាក់ទំនងដ៏ជិតស្និទ្ធរវាង **"ទីក្រុងស្អាត និងទេសចរណ៍"** **"ទីក្រុង និងសុខមាលភាពរបស់ប្រជាពលរដ្ឋ"** ពោលគឺការរីកចម្រើននៃទីក្រុងនឹងផ្តល់ឥទ្ធិពលជាវិជ្ជមានដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ដោយហេតុថាទីក្រុងគឺជាបណ្តុំដ៏សំខាន់ ទាំងសម្រាប់ការរស់នៅ ការសម្រាកលំហែ សកម្មភាពទេសចរណ៍នានា សកម្មភាពពាណិជ្ជកម្ម សេដ្ឋកិច្ចនយោបាយ និងវប្បធម៌ជាដើម។ល។ ជោគជ័យនៃចលនាប្រឡងប្រណាំងទីក្រុងស្អាតនឹងមិនត្រឹមតែចូលរួមដល់ការលើកកម្ពស់គុណភាពសេវាកម្ម និងផលិតផលទេសចរណ៍នៅតាមបណ្តាទីក្រុង និងទីប្រជុំជននានាប៉ុណ្ណោះទេ តែថែមទាំងចូលរួមលើកកម្ពស់កិត្យានុភាពរបស់កម្ពុជាជាគោលដៅទេសចរណ៍កម្ពុជានៅក្នុងតំបន់ និងសកលលោកថែមទៀតផង។ ទន្ទឹមនេះ

ជោគជ័យនៃចលនាប្រឡងប្រណាំងទីក្រុងស្អាតក៏ជាកត្តាកំណត់ចូលរួមធានាដល់ការអភិវឌ្ឍកម្ពុជាប្រកបដោយនិរន្តរភាព ការទទួលខុសត្រូវ និងគ្រប់ជ្រុងជ្រោយ។

ជាមួយគ្នានេះផងដែរ ជោគជ័យនៃវិស័យទេសចរណ៍ក៏នឹងចូលរួមដល់ការអភិវឌ្ឍទីក្រុង តាមរយៈការនាំមកនូវកាល្អានុវត្តភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគគំរូថ្មីនៃការអភិវឌ្ឍនគរូបនីយកម្ម ការអភិរក្សបេតិកភណ្ឌទីក្រុង ការគិតគូរពីនិរន្តរភាពបរិស្ថាន ភាពស្អាត និងភាពបៃតង ការកសាងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ចាំបាច់នានាបំពេញដល់សេចក្តីត្រូវការរបស់ភ្ញៀវទេសចរជាដើម។ល។ ដែលទាំងអស់នេះនឹងជួយជំរុញឲ្យទីក្រុងកាន់តែមានភាពរស់រវើក កាន់តែមានឧត្តមភាពសម្រាប់ការរស់នៅ ការប្រកបធុរកិច្ច និងការទស្សនាកម្សាន្ត ដែលជាការចូលរួមដ៏សំខាន់មួយ ក្នុងការសម្រេចបាននូវ**គោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០** របស់អង្គការសហប្រជាជាតិ (UN) ក្នុងនោះ **គោលដៅទី១១** បានចែងអំពីការខិតខំរួមគ្នាក្នុងការអភិវឌ្ឍទីក្រុងឲ្យមាននិរន្តរភាព ប្រកបដោយសន្តិសុខ សុវត្ថិភាព ស្ថិរភាព និងប្រកបដោយបរិយាបន្ន (Make cities inclusive, safe, resilient and sustainable)។ លើសពីនេះទៀត ទីក្រុងទេសចរណ៍ទាំងអស់ត្រូវបន្តរៀបចំហេដ្ឋារចនាសម្ព័ន្ធ សម្បទា ផលិតផល និងសេវាទេសចរណ៍ សម្រាប់សម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរដែលជាជនពិការ ទេសចរវ័យចំណាស់ ស្ត្រីមានផ្ទៃពោះ និងកុមារជាដើម ស្របតាមនិន្នាការតំបន់អាស៊ានក្នុងការជំរុញ **"ទេសចរណ៍សម្រាប់ទាំងអស់គ្នា"** (Tourism for All)។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនៃពិធីប្រកាសជ័យលាភីទីក្រុងស្អាតលើកទី២ នេះ ខ្ញុំសូមសម្តែងនូវការអបអរសាទរចំពោះក្រុង-ខណ្ឌជ័យលាភីទាំងអស់ ដែលទទួលបានការវាយតម្លៃជាទីក្រុងស្អាតរបស់កម្ពុជា និងសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជធានី-ខេត្ត រដ្ឋបាលក្រុង-ខណ្ឌ និងគ្រប់ភាគីពាក់ព័ន្ធទាំងរដ្ឋ ឯកជន ដៃគូអភិវឌ្ឍន៍ ពិសេសការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ និងប្រជាពលរដ្ឋគ្រប់រូបដែលជាកត្តាកំណត់ជោគជ័យមិនអាចខ្វះបាននៅក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាតនេះ ឬអាចនិយាយបានមួយបែបទៀតថា **"ទីក្រុងស្អាតត្រូវផ្តើមចេញពីយើងទាំងអស់គ្នា ដោយត្រូវរួមគិត រួមធ្វើ រួមទទួលខុសត្រូវ"**។

ខ្ញុំសូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ពិសេសគ្រប់ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ បងប្អូន ប្រជាពលរដ្ឋ និងជនរួមជាតិទាំងអស់មេត្តាបន្តផ្តល់ការគាំទ្រ និងចូលរួមអនុវត្តឱ្យបានផុលផុសប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់នូវចលនាប្រឡងប្រណាំងទីក្រុងស្អាត សំដៅធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍បៃតង ប្រកបដោយគុណភាព និរន្តរភាព និងភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ សក្តិសមទៅនឹងកិត្តិនាម **"កម្ពុជា៖ ព្រះរាជាណាចក្រអច្ឆរិយៈ"**។ ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងបន្តសហការចូលរួមគាំទ្រ ឧបត្ថម្ភ និងអនុវត្តចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋាន សេវាល្អ បដិសណ្ឋារកិច្ចល្អ"** និងរាល់យុទ្ធនាការនានា ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ចលនាប្រឡងប្រណាំងទីក្រុងស្អាត ស្របតាមប្រធានបទ **"ទីក្រុងស្អាត ដើម្បីទាំងអស់គ្នា"**។

ខ្ញុំក៏សូមយកឱកាសក្នុងពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតឆ្នាំ២០១៨ នេះ សូមស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិពីគ្រប់ទិសទីមកទស្សនាកម្សាន្តនៅព្រះរាជាណាចក្រកម្ពុជា ហើយសូមអំពាវនាវដល់ជនរួមជាតិឱ្យចូលរួមគាំទ្រសកម្មភាពទេសចរណ៍ ដោយអញ្ជើញធ្វើដំណើរកម្សាន្ត ទស្សនាតំបន់ទេសចរណ៍នានានៅទូទាំងប្រទេស ដើម្បីចូលរួមចំណែកជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ ជំរុញសកម្មភាពសេដ្ឋកិច្ចផ្ទៃក្នុងផង និងបង្កើនការស្រលាញ់ជាតិមាតុភូមិ សាមគ្គីភាព មិត្តភាព និងចែករំលែកផលប្រយោជន៍ ដោយសមធម៌ជូនដល់ប្រជាជននៅមូលដ្ឋានផង។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរជនរួមជាតិទាំងអស់ជួបតែពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមជូនពរឲ្យទិវាជាតិទីក្រុងស្អាត និងចលនាប្រឡងប្រណាំងទីក្រុងស្អាត ប្រព្រឹត្តទៅប្រកបដោយជោគជ័យជានិច្ចនិរន្តរ៍។

ថ្ងៃ អង្គារ ៦រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១.
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៨

ហ៊ុន សែន